# ព្រះរាជក្រម

នស/រកម/០៨០៩/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុរោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីវិស័យផ្លាស់ប្តូរហត្ថពលកម្មរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគូវ៉ែត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើអនុស្សរណៈនៃការយោគយល់គ្នា
# ស្តីពីវិស័យផ្លាស់ប្តូរហត្ថពលកម្ម រវាងរាជរដ្ឋាភិបាល
# នៃព្រះរាជាណាចក្រកម្ពុជា និង
# រដ្ឋាភិបាលនៃរដ្ឋគូវ៉ែត

**មាត្រា ១.-**

អនុម័តយល់ព្រមលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីវិស័យផ្លាស់ប្តូរហត្ថពលកម្ម រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគូវ៉ែត ដែលបានចុះហត្ថលេខានៅទីក្រុងគូវ៉ែត នាថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៨០៤.០៣៧

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ហត្ថលេខា

ទង សូត

លេខ: ៧៦២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០០៤
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# អនុស្សរណៈនៃការយោគយល់គ្នា

## ស្តីពី

## វិស័យផ្លាស់ប្តូរហត្ថពលកម្ម

## រវាង

## រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃរដ្ឋគូវ៉ែត

រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង រដ្ឋាភិបាលនៃរដ្ឋគូវ៉ែត ដែលតំណាងដោយ ក្រសួងសង្គមកិច្ច និងការងារ ចាប់ពីពេលនេះតទៅ ហៅថា " ភាគី "

ដោយបានកំណត់ច្បាស់លាស់ អំពីទំនាក់ទំនងជាមិត្តភាព រវាងរាជរដ្ឋាភិបាល និងពលរដ្ឋ នៃប្រទេសទាំងពីរ

ក្នុងបំណងបង្កើតទំនាក់ទំនងទ្វេភាគី ដោយឈរលើផលប្រយោជន៍ទៅវិញទៅមក រវាងគូភាគី

ក្នុងបំណងបង្កើនកិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួល ក្នុងវិស័យផ្លាស់ប្តូរហត្ថពលកម្ម

ភាគីទាំងពីរបានព្រមព្រៀងគ្នា:

### ប្រការ(១)

ពង្រឹងកិច្ចសហប្រតិបត្តិការក្នុង វិស័យ ការងារ និង មុខរបរ និង កិច្ចអភិវឌ្ឍន៍ហត្ថពលកម្ម ។

### ប្រការ(២)

បង្កភាពងាយស្រួលរាល់សេវានានា ដើម្បីអនុម័ត និងអភិវឌ្ឍកិច្ចសហប្រតិបត្តិការបែបនេះ នៅក្នុងក្របខណ្ឌនៃច្បាប់ វិធាន និង បទបញ្ញាទាំងឡាយ ជាធរមាន ដែលអនុវត្តបាន របស់ប្រទេសទាំងពីរ ។

### ប្រការ(៣)

បង្កភាពងាយស្រួលរាល់ចលនា និងការនាំយកនូវ ហត្ថពលកម្មនៃជាតិរៀង១ខ្លួន ស្ថិតក្នុងក្របខណ្ឌនៃច្បាប់ វិធាន និងបទបញ្ញាទាំងឡាយ ជាធរមាន ដែលអាចអនុវត្តបាន របស់ប្រទេសនីមួយៗ ។

ប្រការ(៤)

ផ្លាស់ប្តូរទស្សនកិច្ច និងកិច្ចពិគ្រោះយោបល់រវាងប្រទេសទាំងពីរ ផ្លាស់ប្តូរទេពកោសល្យ និងចំណេះធ្វើ នៅក្នុងវិស័យ នៃការបង្កើតឱកាសការងារ និងមុខរបរ ។

ប្រការ(៥)

លក្ខខណ្ឌជាមូលដ្ឋាននៃមុខរបរ និងសិទ្ធិ និងភារកិច្ច របស់និយោជក និងនិយោជិក (កម្មករ) ត្រូវចែងឱ្យបានច្បាស់លាស់ក្នុងកិច្ចសន្យាការងារ ដោយស្របទៅតាមច្បាប់ និងបទបញ្ជា ដែលជាប់ទាក់ទងនៃប្រទេសម្ចាស់ផ្ទះ ។

ប្រការ(៦)

និយោជកនៃប្រទេសម្ចាស់ផ្ទះ ត្រូវធានាអំពីការចេញប័ណ្ណការងារ ស្របទៅតាមឯកសារដែលបានដាក់ជូនដែល រួមមានទាំងកិច្ចសន្យាការងារមួយច្បាប់ផង នៅពេលស្នើសុំការសម្រេចទទួលយក ក្នុងរយៈពេល ពីរ (២)ខែ នៅពេល ដែលកម្មករទៅដល់ប្រទេសនេះ ។

ប្រការ(៧)

ក្រុមការងាររួមមួយនឹងត្រូវបង្កើតឡើង ដើម្បីទទួលអនុវត្តកិច្ចការដូចតទៅ:

ក) ធានាការអនុវត្តអនុស្សរណៈនេះ

ខ) លើកសំណើសុំពិនិត្យមើលឡើងវិញអនុស្សរណៈនេះទៅតាមការចាំបាច់ និងដោះស្រាយរាល់បញ្ហា ឬការលំបាកនានា ក្នុងការអនុវត្តអនុស្សរណៈ និង

គ) សិក្សាអំពីលទ្ធភាពកើតមានឱកាសការងារ និងលើកអនុសាសន៍ ជាវិធានការណ៍នៃកិច្ចសហប្រតិបត្តិការបច្ចេកទេស ការបណ្តុះបណ្តាល ការពង្រឹងមុខជំនាញ និងការផ្តល់បុគ្គលិកជំនាញបច្ចេកទេស ទៅដល់គ្រប់ផ្នែក ដើម្បីផលប្រយោជន៍ទៅវិញទៅមករបស់ភាគីទាំងពីរ ។

ក្រុមការងាររួមត្រូវជួបប្រជុំគ្នា ម្តងក្នុងមួយឆ្នាំ នៅប្រទេសណាមួយ តាមបែបប្តូរវេន និងតាមការចាំបាច់តាមសំណើ របស់ភាគីណាមួយ ក្នុងចំណោមភាគីទាំងពីរ ។

ប្រការ(៨)

អនុស្សរណៈនៃការយោគយល់គ្នានេះចូលជាធរមានបញ្ញត្តិ ចាប់ពីកាលបរិច្ឆេទ ដែលភាគីណាមួយក្នុងចំណោមភាគីទាំង២បានជូនដំណឹងចុងក្រោយទៅភាគីមួយទៀត ស្របទៅតាមនីតិវិធីនៃច្បាប់ជាតិ ដែលបានតម្រូវនៅក្នុងការអនុវត្តនេះ ។

អនុស្សរណៈនៃការយោគយល់គ្នានេះ អាចនឹងត្រូវធ្វើវិសោធនកម្មបាន អាស្រ័យដោយការព្រមព្រៀងគ្នារវាងភាគីទាំងពីរ ហើយវិសោធនកម្មនេះត្រូវធ្វើឡើងស្របទៅតាមនីតិវិធី ដែលបានកំណត់ក្នុងកឋាខណ្ឌដំបូងនៃប្រការនេះ។

អនុស្សរណៈនៃការយោគយល់គ្នានេះមានសុពលភាពរយៈពេលបួន(៤)ឆ្នាំ ហើយនឹងត្រូវបន្តសុពលភាពតទៅទៀត ជាស្វ័យប្រវត្តក្នុងរយៈពេលដូចគ្នា ឬក្នុងរយៈពេលណាមួយទៀត អាស្រ័យទៅតាមការស្នើសុំរបស់ភាគីណាមួយក្នុងចំណោមភាគីទាំង២ តាមរយៈការជូនដំណឹងតាមផ្លូវការទូត ទៅតាមបំណងបញ្ចប់របស់ភាគីនោះ ដោយសំណើនោះត្រូវធ្វើឡើងឱ្យបាន ប្រាំមួយ(៦)ខែ មុនកាលបរិច្ឆេត ដែលអនុស្សរណៈនេះ អស់សុពលភាព ។

បានចុះហត្ថលេខានៅ ទីក្រុងគូវ៉ែត នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩ ជាពីរ(២)ច្បាប់ដើម ដែលក្នុងមួយច្បាប់ៗមានជាភាសាខ្មែរ អារ៉ាប់ និងអង់គ្លេស ហើយអត្ថបទទាំងអស់មានតម្លៃស្មើគ្នា។ ក្នុងករណី មានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវប្រើប្រាស់ជាឯកសារគោល ។

**តំណាងរាជរដ្ឋាភិបាលកម្ពុជា**

**ចេង សូត**

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តំណាងរដ្ឋាភិបាលនៃរដ្ឋគូវ៉ែត**

**បេធាទី បាដី អេហ្វ. អាល់_ដូវែឡា**

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច និង ការងារ**